# <u>សេចក្តីណែនាំអំពីការបំពេញពាក្យស្នើសុំរបស់អ្នកទទួលសេវាក្នុងកម្មវិធី IHSS ដែលស្នើសុំការកំណត់ម៉ោងដែលបានអនុញ្ញាត ទៅឲ្យអ្នកផ្តល់សេវា (SOC 838)</u>

## <u>អ្នកទទួលសេវាក្នុងកម្មវិធី IHSS</u>

1. សូមកំណត់ចំនួនម៉ោង ឲ្យអ្នកផ្តល់សេវារបស់លោកអ្នក ដើម្បីឲ្យម៉ោង ដែលបានកំណត់ឲ្យអ្នកផ្តល់សេវារបស់លោកអ្នកទាំងអស់ **ស្មើ**នឹងចំនួនម៉ោងប្រចាំខែសរុបដែលបានអនុញ្ញាតឲ្យលោកអ្នក។

2. សូមបំពេញទម្រង់ SOC 838 សម្រាប់អ្នកផ្តល់សេវា**ម្នាក់ៗ** “ដែលកំពុងផ្តល់សេវា”។
3. មានរបៀបពីរយ៉ាង ដើម្បីកំណត់ចំនួនម៉ោងឲ្យអ្នកផ្តល់សេវារបស់លោកអ្នកៈ

   *a.* លោកអ្នកអាចកំណត់ចំនួនម៉ោង/នាទីដែលបានអនុញ្ញាតទាំងអស់របស់លោកអ្នក ឲ្យអ្នកផ្តល់សេវាម្នាក់ៗ។ នេះនឹងអនុញ្ញាតឲ្យលោកអ្នកកែប្រែម៉ោង ដែលអ្នកផ្តល់សេវាម្នាក់ៗ បម្រើការងាជាប្រចាំខែ ដោយមិនចាំបាច់ជូនដំណឹងមកខោនធីទេ។ ***លោកអ្នកនឹងទទួលខុសត្រូវគ្រប់គ្រងម៉ោង ដែលអ្នកផ្តល់សេវាបម្រើការងារ ដើម្បីធានាថា ចំនួនម៉ោងសរុបសម្រាប់អ្នកផ្តល់សេវាទាំងអស់របស់លោកអ្នក មិនលើសចំនួនម៉ោងសរុបដែលបានអនុញ្ញាតប្រចាំខែឡើយ***។

> **<u>ឧទាហរណ៍ A</u>**
> លោកអ្នកមានចំនួនម៉ោង 100:00 ម៉ោង។ លោកអ្នកមានអ្នកផ្តល់សេវាពីរនាក់ គឺ Jane និង John។ បំពេញទម្រង់ SOC 838 ពីរ<u>ដោយឡែកពីគ្នា</u> សម្រាប់ Jane និង John៖ (1) បញ្ចូល 100:00 ម៉ោងលើទម្រង់ SOC 838 របស់ Jane និង (2) បញ្ចូល 100:00 ម៉ោង លើទម្រង់ SOC 838 របស់ John។

<u>**ឬ**</u>

   *b.* លោកអ្នកអាចកំណត់ចំនួនម៉ោងជាក់លាក់ សម្រាប់អ្នកផ្តល់សេវាម្នាក់ៗ ដែលនៅពេលបូកបញ្ចូលគ្នា ស្មើនឹងចំនួនម៉ោង/នាទីសរុបដែលបានអនុញ្ញាតរបស់លោកអ្នក ក្នុងមួយខែ។

> **<u>ឧទាហរណ៍ B</u>**
> លោកអ្នកមានចំនួនម៉ោង 100:00 ។ លោកអ្នកមានអ្នកផ្តល់សេវាពីរនាក់ គឺ Jane និង John។ អ្នកកំណត់ 30:00 ម៉ោង សម្រាប់ Jane និង 70:00 ម៉ោង សម្រាប់ John។
> បំពេញទម្រង់ SOC 838 <u>ពីរដោយឡែកពីគ្នា</u> សម្រាប់ Jane និង John៖ (1) បញ្ចូល 30:00 ម៉ោងលើទម្រង់ SOC 838 របស់ Jane និង (2) បញ្ចូល 700:00 ម៉ោង លើទម្រង់ SOC 838 របស់ John។

4. ត្រង់កន្លែង “សម្រាប់ខោនធីប្រើប៉ុណ្ណោះ” សូមបញ្ជាក់ពីកាលបរិច្ឆេទមានប្រសិទ្ធិភាព សម្រាប់ម៉ោងប្រចាំខែដែលបានកំណត់។

5. សូមបញ្ជូនទម្រង់ SOC 838 ដែលបានបំពេញរួច មកវិញ ព្រមទាំងកញ្ចប់ឯកសារដែលបានភ្ជាប់មកជាមួយ។

6. លោកអ្នកអាចស្នើសុំទម្រង់ SOC 838 បន្ថែម ដោយទូរស័ព្ទទៅ Payroll Line លេខ 510-577-1877 ទាញយកទម្រង់លើវេបសាយ ឬមកយកទម្រង់ដោយផ្ទាល់ នៅការិយាល័យ IHSS ។

7. ប្រសិនបើលោកអ្នកត្រូវការជួល និងចុះឈ្មោះអ្នកផ្តល់សេវាថ្មី លោកអ្នកអាចស្នើសុំកញ្ចប់ឯកសារចុះឈ្មោះអ្នកផ្តល់សេវាថ្មី ដោយទូរស័ព្ទទៅ Payroll Line លេខ 510-577-1877 ទាញយកកញ្ចប់ឯកសារលើវេបសាយ ឬមកយកកញ្ចប់ឯកសារដោយផ្ទាល់ នៅការិយាល័យ IHSS ។

សម្រាប់ជំនួយបន្ថែម សូមហៅទូរស័ព្ទទៅ IHSS Payroll Department លេខ 510-577-1877 ។ សូមអរគុណ។